
Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org

## 3.01 **អ្នកស៊ើបការណ៍ទាំង១២នាក់**

ព្រះអម្ចាស់តែងតែថែរក្សាប្រជាជនរបស់ទ្រង់។ នៅពេលដែលប្រជាជនរបស់ព្រះអង្គជាជនជាតិអ៊ីស្រាអែលបានស្រែករកជំនួយពីទ្រង់ នៅពេលពួកគេនៅស្រុកអេស៊ីប ព្រះអង្គបានចាត់លោកម៉ូសេឲ្យទៅជួយរំដោះពួកគេ។ ព្រះបានធ្វើការអស្ចារ្យជាច្រើននៅស្រុកអេស៊ីប ដើម្បីបញ្ចុះបញ្ចូលព្រះមហាក្សត្រឱ្យដោះលែងប្រជាជនទ្រង់។ នៅទីបំផុតលោកម៉ូសេបាននាំជនជាតិអ៊ីស្រាអែលចេញពីស្រុកអេស៊ីប ហើយព្រះបានសន្យាថានឹងនាំពួកគេទៅកាន់ទឹកដីថ្មី គឺទឹកដីកាណាន។ នៅតាមផ្លូវពួកគេបានជួបបញ្ហា និងមានការត្អូញត្អែរជាច្រើន។ មានពេលខ្លះពួកគេមិនស្តាប់បង្គាប់ព្រះអម្ចាស់ទេ។ ប៉ុន្តែម៉ូសេនៅតែបន្តធ្វើអ្វីដែលព្រះបានបង្គាប់ឲ្យគាត់ធ្វើ ដោយការដឹកនាំប្រជាជនទាំងនោះទៅដល់ស្រុកកាណាន។ នៅពេលដែលពួកគេបានទៅជិតស្រុកកាណានហើយ ព្រះបានប្រាប់លោកម៉ូសេឲ្យចាត់បុរស ១២ នាក់ ដែលជាអ្នកស៊ើបការណ៍ ឲ្យទៅមើលទឹកដីនោះ។ ព្រះបានដឹងថា នឹងមានមនុស្សផ្សេងទៀតនៅទីនោះ មនុស្សដែលមិនជឿលើព្រះ ហើយជាមនុស្សមានបាប។ ព្រះនឹងជួយជនជាតិអ៊ីស្រាអែលដណ្តើមយកទឹកដីនោះ។ នេះជាទឹកដីដែលព្រះអង្គបានសន្យាជាមួយប្រជារាស្ត្ររបស់ព្រះអង្គ។ នៅពេលដែលលោកម៉ូសេចាត់អ្នកស៊ើបការណ៍ទាំង ១២ នាក់ ឱ្យទៅស្រុកកាណាន លោកបានប្រាប់ពួកគេឱ្យមើលអ្វីៗទាំងអស់នៅទីនោះ។ លោកម៉ូសេមានប្រសាសន៍ថា៖ ចូរមើលទឹកដីនោះ តើយើងអាចដាំដំណាំបានទេ? យកគំរូអាហារដែលដុះនៅទីនោះមកវិញ និងសង្កេតមើលមនុស្សនៅទីនោះ។ មើលថាតើពួកគេខ្លាំងឬខ្សោយ ហើយប្រាប់យើងអំពីកន្លែងដែលពួកគេរស់នៅ។ អ្នកស៊ើបការណ៍ទាំងដប់ពីរនាក់បាននៅឯស្រុកកាណានអស់រយៈពេល៤០ថ្ងៃ។ ពួកគេបានឃើញអ្វីៗទាំងអស់។ អ្នកស៊ើបការណ៍ពីរនាក់ដែលមានឈ្មោះ យ៉ូស្វេ និងកាលែប បានត្រឡប់មកវិញដោយក្តីរំភើបជាខ្លាំង។ ពួកគេបាននាំយកអាហារល្អៗមកវិញ។ ពួកគេនិយាយថា “ប្រជាជននៅទីនោះមានភាពរឹងមាំណាស់ ប៉ុន្តែយើងដឹងថាព្រះបានសន្យាជាមួយយើងនូវទឹកដីនេះហើយ យើងអាចប្រយុទ្ធជាមួយវាឈ្នះបាន។ កុំភ័យខ្លាចអី! ព្រះអម្ចាស់គង់នៅជាមួយយើងហើយ”។ ប៉ុន្តែអ្នកស៊ើបការណ៍ ១០ នាក់ឯទៀតភ័យខ្លាច។ ពួកគេបាននិយាយថា “មនុស្សនៅទីនោះមានមាឌធំដូចយក្ស ពួកគេអាចខ្លាំងពេកសម្រាប់យើងដើម្បីយកឈ្នះបាន។ យើងទាំងអស់គ្នានឹងត្រូវស្លាប់។ យើងប្រៀបដូចជាស្រមោចសម្រាប់ពួកគេចឹង។ អ្នកស៊ើបការណ៍ទាំង ១០ នាក់នេះបានបន្តនិយាយរឿងគួរឱ្យខ្លាចអំពីអ្វីដែលពួកគេបានឃើញ។ ពួកគេមិនជឿថា ព្រះអាចជួយពួកគេដណ្តើមយកទឹកដីនោះបានទេ។ ប្រជាជនបានជឿបុរសទាំងដប់នាក់នេះ។ ពួកគេចាប់ផ្តើមស្រែកថ្ងូរ និងត្អូញត្អែរថា ហេតុអ្វីបានជាលោកម៉ូសេនាំពួកគេចេញពីស្រុកអេស៊ីបដូច្នេះ។ ពួកគេបាននិយាយថា “ចូរជ្រើសរើសមេដឹកនាំថ្មីទៅ” ។ អ្នកថ្មីអាចនាំយើងត្រឡប់ទៅប្រទេសអេស៊ីបវិញបាន។ លោកម៉ូសេបានជួបជាមួយបងប្រុសរបស់គាត់ គឺលោកអើរ៉ុន និងអ្នកស៊ើបការណ៍ពីរនាក់ដែលជឿលើអំណាចរបស់ព្រះអម្ចាស់ គឺយ៉ូស្វេ និងកាលែប។ ពួកគេបានព្យាយាមបញ្ចុះបញ្ចូលប្រជាជនកុំឱ្យភ័យខ្លាច។ ប៉ុន្តែប្រជាជនខឹងនឹងពួកគេណាស់ ពួកគេមិនជឿពួកលោកទេ។ ប្រជាជនទាំងនោះចាប់ផ្តើមរៀបគម្រោងការសម្លាប់បុរស ដែលកោតខ្លាចព្រះទាំងនេះ។ បន្ទាប់មក ពន្លឺនៃសិរីរុងរឿងរបស់ព្រះបានលេចមក ឲ្យមនុស្សទាំងអស់ឃើញ។ ព្រះបានមានបន្ទូលទៅកាន់ម៉ូសេថា “តើជនទាំងឡាយនេះ នឹងនៅតែមើលងាយអញ ដល់កាលណាទៀត តើដល់កាលណាទៀតដែលគេនៅតែមិនជឿដល់អញ ទោះបើឃើញអស់ទាំងទីសំគាល់ ដែលអញបានធ្វើនៅកណ្តាលគេជាច្រើនម្ល៉េះផង ដូច្នេះ អញនឹងវាយគេ ដោយជំងឺអាសន្នរោគ ហើយនឹងកាត់កាល់គេចោលចេញ”។ លោកម៉ូសេទូលអង្វរទៅព្រះថា៖ “សូមអត់ទោសដល់ប្រជាជនទាំងនេះពីការដែលមិនស្តាប់បង្គាប់ និងអំពើទុច្ចរិតរបស់ពួកគេផង ទូលបង្គំដឹងថាទ្រង់នៅតែស្រឡាញ់ពួកគេដូចដែលទ្រង់ធ្លាប់មាន”។ ព្រះបានប្រាប់ម៉ូសេថា ទ្រង់នឹងអភ័យទោសដល់ប្រជាជនទាំងនោះ ទោះជាពួកគេមិនជឿលើទ្រង់ ពីព្រោះពួកគេខ្លាចនឹងទៅស្រុកដែលទ្រង់បាននាំពួកគេទៅ ហើយដោយសារពួកគេមិនទុកចិត្តទ្រង់ ដើម្បីជួយពួកគេយកឈ្នះប្រជាជននៅទីនោះ ទ្រង់នឹងធ្វើឱ្យពួកគេវង្វេងនៅវាលរហោស្ថាន៤០ឆ្នាំទៀត ប្រជាជនដែលរស់នៅគ្រានោះនឹងមិនអាចឃើញទឹកដីសន្យានៃស្រុកកាណានបានឡើយ។ មានតែកូនៗរបស់គេទេដែលអាចចូលទឹកដីនោះ និងរស់នៅទីនោះជាមួយគ្រួសារគេបាន។ សូម្បីតែអ្នកស៊ើបការណ៍១០នាក់ផ្សេងទៀត ក៏មិនអាចឃើញទឹកដីសន្យាដែរ។ ពួកគេបានស្លាប់ដោយសារជំងឺ។ ប៉ុន្តែ ព្រះបានអនុញ្ញាតឲ្យយ៉ូស្វេ និងកាលែបចូលស្រុកកាណានបាន ពីព្រោះពួកគេបានទុកចិត្តលើទ្រង់។ នៅពេលដែលយើងទុកចិត្តលើព្រះអម្ចាស់ នោះទ្រង់នឹងជួយយើង។ **(ជនគណនា ១៣ និង ១៤)**

# 3.01 អ្នកស៊ើបការណ៍ទាំង១២ - សេចក្ដីណែនាំសម្រាប់គ្រូបង្រៀន
## កំណាត់សម្គាល់

១) ព្រះអម្ចាស់បានចាត់លោកម៉ូសេឱ្យទៅស្រុកអេស៊ីប ដើម្បីជួយសង្គ្រោះប្រជាជនអ៊ីស្រាអែល ជាប្រជារាស្ត្ររបស់ទ្រង់ ។ ព្រះបានសន្យា ថា នឹងឲ្យទឹកដីថ្មីមួយដល់ពួកគេរស់នៅ គឺស្រុកកាណាន។

២) នៅពេលដែលជនជាតិអ៊ីស្រាអែលបានទៅជិតស្រុកកាណានហើយ លោកម៉ូសេបានចាត់បុរសដប់ពីរនាក់ ដែលជាអ្នកស៊ើបការណ៍ទាំងដប់ពីររូប ឲ្យទៅមើលទឹកដីនោះ ហើយយកមករាយការណ៍នូវអ្វីដែលពួកគេបានឃើញនៅទីនោះ។

៣) អ្នកស៊ើបការណ៍ ១២ នាក់បានចំណាយពេល ៤០ ថ្ងៃនៅស្រុកកាណាន។ នៅពេលពួកគេត្រឡប់មកវិញ អ្នកស៊ើបការណ៍ពីរនាក់បាននាំយកអាហារល្អៗមកវិញ។ ពួកគេបាននិយាយថា ប្រជាជននៅទីនោះខ្លាំង ប៉ុន្តែព្រះនឹងជួយជនជាតិអ៊ីស្រាអែលដណ្តើមយកទឹកដីនោះបាន។

៤) អ្នកស៊ើបការណ៍ ១០ នាក់ផ្សេងទៀតភ័យខ្លាច។ ពួកគេបាននិយាយថា មានយក្សនៅទីនោះ។ ប្រជាជននៅទីនោះមានកម្លាំងខ្លាំងពេកហើយ ដើម្បីយកឈ្នះពួកគេ។ ពួកគេបានបញ្ចុះបញ្ចូលប្រជាជនឱ្យមានការភ័យខ្លាចផងដែរ។

៥) ព្រះបានខឹងនឹងប្រជាជនណាស់។ ទ្រង់ចង់បំផ្លាញពួកគេចោល។ តែលោកម៉ូសេបានសុំព្រះអភ័យទោសឲ្យពួកគេ។ ព្រះបានប្រាប់លោកម៉ូសេថា ទ្រង់នឹងអភ័យទោសឱ្យពួកគេ ប៉ុន្តែពួកគេនឹងមិនអាចចូលទឹកដីកាណានដែលបានសន្យាទេ។ លើសពីនេះទៀត ប្រជាជនទាំងនេះនឹងត្រូវវង្វេងនៅវាលខ្សាច់អស់រយៈពេល ៤០ ឆ្នាំទៀត។

## សំណួរ

1) តើទឹកដីណា ដែលព្រះបានសន្យាដល់ប្រជារាស្ត្ររបស់ព្រះអង្គ គឺជាអ៊ីស្រាអែល?
2) តើម៉ូសេបានបញ្ជូនបុរសប៉ុន្មាននាក់ ដើម្បីទៅស៊ើបមើលទឹកដីកាណាន?
3) តើអ្នកស៊ើបការណ៍ពីរនាក់ បាននិយាយអ្វីខ្លះអំពីស្រុកកាណាន?
4) តើអ្នកស៊ើបការណ៍ ១០ នាក់ផ្សេងទៀត បាននិយាយអ្វីអំពីស្រុកកាណាន?
5) តើប្រជាជនចង់ធ្វើអ្វីនៅពេលពួកគេបានឮសេចក្តីរាយការណ៍ពីអ្នកស៊ើបការណ៍ទាំង(១០នាក់)នោះ?
6) តើព្រះមានបន្ទូលថានឹងមានអ្វីកើតឡើងចំពោះមនុស្សដែលមិនជឿទុកចិត្តលើទ្រង់?

## ចម្លើយ

1) ព្រះបានសន្យានឹងរាស្ត្ររបស់ទ្រង់ គឺប្រជាជនអ៊ីស្រាអែលនឹងបានទឹកដីកាណាន។
2) លោកម៉ូសេបានចាត់បុរសដប់ពីរនាក់ឱ្យធ្វើជាអ្នកស៊ើបការណ៍ដើម្បីទៅមើលទឹកដីនោះ។
3) អ្នកស៊ើបការណ៍ពីរនាក់បាននិយាយថា ព្រះនឹងជួយជនជាតិអ៊ីស្រាអែលដណ្តើមយកទឹកដីនោះបាន។
4) អ្នកស៊ើបការណ៍ ១០ នាក់ផ្សេងទៀតបាននិយាយថា ប្រជាជននៅទីនោះខ្លាំងពេកមិនអាចយកឈ្នះបានទេ។
5) ប្រជាជនចង់ត្រឡប់ទៅស្រុកអេស៊ីបវិញ។
6) ព្រះបានមានបន្ទូលថា ប្រជាជននឹងត្រូវវង្វេងនៅវាលខ្សាច់អស់រយៈពេល ៤០ ឆ្នាំទៀត ពួកគេនឹងមិនអាចចូលទៅទឹកដីសន្យាបានទេ។



Kids of Destiny®
Reaching the Next Generation

www.kidsofdestiny.org